ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាអាជ្ញាកណ្តាល
THE ARBITRATION COUNCIL

លេខ និង ឈ្មោះសំណុំរឿង ៖ ០១៩/២១ - ត្រាយអាំហ៊្វិន ជ្រេហ្គន
កាលបរិច្ឆេទនៃសេចក្តីបង្គាប់ ៖ ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០២១

# សេចក្តីបង្គាប់អាជ្ញាកណ្តាល

(ធ្វើឡើងស្របតាមមាត្រា ៣១៣ នៃច្បាប់ស្តីពីការងារ)

## សមាសភាពក្រុមអាជ្ញាកណ្តាល

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីនិយោជក ៖ **អ៊ឹង សុទ្ធី**

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីកម្មករនិយោជិត ៖ **អន ណាន**

ប្រធានក្រុមអាជ្ញាកណ្តាលជ្រើសរើសឡើងដោយអាជ្ញាកណ្តាលទាំងពីរខាងលើ ៖ **រុន សារ៉ាយ**

## ភាគីនៃវិវាទ

### ១- ភាគីនិយោជក

ឈ្មោះ ៖ **ក្រុមហ៊ុន ត្រាយអាំហ្វិន ជ្រេហ្គន (ខេមបូឌា) ឯ.ក**

អាសយដ្ឋាន ៖ ភូមិខ្នារទង់ ឃុំកុមាររាជា ស្រុកបាទី ខេត្តតាកែវ

ទូរស័ព្ទ ៖ ០១០ ៣២ ១១ ៨៨ ទូរសារ ៖ គ្មាន

តំណាងភាគីនិយោជកចូលរួមសវនាការ៖

| | | |
|---|---|---|
| ១- | លោក Lin Kaun Yu | អ្នកគ្រប់គ្រងធនធានមនុស្ស |
| ២- | លោកស្រី ម៉ៅ សោភា | ជំនួយការរដ្ឋបាល |
| ៣- | លោកស្រី សៅ សុក័ណ្ណ | អ្នកបកប្រែ |

### ២- ភាគីកម្មករនិយោជិត

ឈ្មោះ ៖ **អ្នកតំណាងភាគីកម្មករនិយោជិតក្នុងការដោះស្រាយវិវាទការងាររួម នៃក្រុមហ៊ុន ត្រាយអាំហ្វិន ជ្រេហ្គន (ខេមបូឌា) ឯ.ក**

អាសយដ្ឋាន ៖ ភូមិខ្នារទង់ ឃុំកុមាររាជា ស្រុកបាទី ខេត្តតាកែវ

ទូរស័ព្ទ ៖ ០៩៩ ៦៨ ៩៧ ៩៤ / ០៩៦ ៧៧ ៦១ ២៣០ ទូរសារ ៖ គ្មាន

តំណាងភាគីកម្មករនិយោជិតចូលរួមសវនាការ៖

| | | |
|---|---|---|
| ១- | លោក អំ ពុទ្ធិ | មន្ត្រីសហព័ន្ធសហជីពស្មារតីកម្មករខ្មែរ |
| ២- | លោក ខែម ផានិត | មន្ត្រីសហព័ន្ធសហជីពស្មារតីកម្មករខ្មែរ |
| ៣- | លោកស្រី សាយ អូន | ប្រធានសហជីពមូលដ្ឋាន |
| ៤- | លោក ប្រាក់ ភក្តី | អនុប្រធានសហជីពមូលដ្ឋាន |

៥- លោក ម៉ុម ពន្លក តំណាងកម្មករនិយោជិត

## បញ្ហាក្នុងវិវាទ

(នៅក្នុងរបាយការណ៍ផ្សះផ្សាមិនសះជា)

១- ភាគីតំណាងកម្មករនិយោជិតនៅតែទាមទារ សូមឱ្យក្រុមហ៊ុនអនុវត្តឡើងវិញ ចំពោះការអនុញ្ញាតឱ្យស្ត្រីមានផ្ទៃពោះទៅពិនិត្យសុខភាព ១ថ្ងៃ ក្នុង១ខែ ដោយរក្សាប្រាក់ឈ្នួល និងប្រាក់អត្ថប្រយោជន៍ផ្សេងៗនៅពេញដដែល ដូចអ្វីដែលក្រុមហ៊ុនធ្លាប់ផ្តល់ឱ្យកម្មករកន្លងមក។ ដោយឡែក ភាគីតំណាងនិយោជកបានបញ្ជាក់ថា ក្រុមហ៊ុនផ្តល់ជូន ៥ម៉ោង នៃម៉ោងធ្វើការ។

២- ភាគីតំណាងកម្មករនិយោជិតនៅតែទាមទារ សូមឱ្យក្រុមហ៊ុនដំឡើងប្រាក់ឈ្នួលចំនួន ២ដុល្លារ ចំពោះប្រធានក្រុម ប្រធានផ្នែក ស៊ុបភើវ៉ាយស័រ ដូចកម្មករទូទៅដែរ ស្របតាមប្រកាសរបស់ក្រសួងស្តីពីការតម្លើងប្រាក់ឈ្នួលអប្បបរមាសម្រាប់ឆ្នាំ២០២១។ ដោយឡែក ភាគីតំណាងនិយោជកបានបញ្ជាក់ថា ក្រុមហ៊ុនផ្តល់ជូនសម្រាប់តែកម្មករធម្មតា ដែលមានប្រាក់ឈ្នួលទាបជាងប្រាក់ឈ្នួលអប្បបរមាដែលក្រសួងកំណត់ប៉ុណ្ណោះ។

៣- ភាគីតំណាងកម្មករនិយោជិតនៅតែទាមទារ សូមឱ្យក្រុមហ៊ុនផ្តល់ប្រាក់ទ្រទ្រង់សុខភាពចំនួន ៥ ដុល្លារ ជូនកម្មករនិយោជិតដែលក្រុមហ៊ុនធ្លាប់អនុវត្តផ្តល់ឱ្យកម្មករកន្លងមក។ ដោយឡែកភាគីតំណាងនិយោជកបានបញ្ជាក់ថា ចំពោះប្រាក់ទ្រទ្រង់សុខភាពចំនួន ៥ដុល្លារ ក្រុមហ៊ុនផ្តល់ជូនសម្រាប់តែកម្មករនិយោជិតចាស់ប៉ុណ្ណោះ សម្រាប់កម្មករនិយោជិតថ្មី ក្រុមហ៊ុនពុំអាចផ្តល់ជូនបានទេ ព្រោះក្រុមហ៊ុនបានបង់ប្រាក់ភាគទានជូន ប.ស.ស រួចហើយ។

## អំណាចយុត្តាធិការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល

ក្រុមប្រឹក្សាអាជ្ញាកណ្តាលទទួលអំណាចក្នុងការចេញសេចក្តីបង្គាប់នេះ ដោយយោងតាមជំពូកទី១២ ផ្នែកទីពីរ (ខ) (មាត្រា ៣០៩ ដល់ ៣១៧) នៃច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ ប្រកាសស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាល លេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ វិធាននៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្តាល ដែលភ្ជាប់ជាឧបសម្ព័ន្ធ នៃប្រកាសលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ និងប្រកាសស្តីពីការតែងតាំងសមាជិកក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ១៨៥/២០ ក.ប/ប្រ.ក.រ.ក ចុះថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០២០ (អាណត្តិទី១៨)។

ការព្យាយាមផ្សះផ្សាវិវាទការងាររួម ដែលជាកម្មវត្ថុនៃសេចក្តីបង្គាប់នេះ ត្រូវបានធ្វើឡើងស្របតាមជំពូកទី១២ ផ្នែកទី២ (ក) នៃច្បាប់ស្តីពីការងារ។ ប៉ុន្តែ ការផ្សះផ្សានោះ ភាគីទាំងពីរមិនបានឯកភាពសះជានឹងគ្នាឡើយ ហើយរបាយការណ៍ស្តីអំពីការដោះស្រាយវិវាទការងាររួមនៃក្រុមហ៊ុន ត្រាយអាំហ្វិន ជ្រេហ្គន (ខេមបូឌា) ឯ.ក លេខ ៥១៥ ក.ប/អក/វក ចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០២១ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋាននៃក្រុមប្រឹក្សា-អាជ្ញាកណ្តាល នៅថ្ងៃទី០៩ ខែសីហា ឆ្នាំ២០២១។

## សវនាការ និង សន្ទេបនីតិវិធី

**ទីកន្លែងសវនាការ ៖** ក្រុមប្រឹក្សាអាជ្ញាកណ្តាល ភូមិគ្រឹះលេខ ៧២ ផ្លូវលេខ ៥៩២ កាច់ជ្រុងផ្លូវលេខ ៣២៧ (ទល់មុខវិទ្យាល័យឥន្ទ្រទេវី), សង្កាត់បឹងកក់ ២, ខណ្ឌទួលគោក, រាជធានីភ្នំពេញ។

**កាលបរិច្ឆេទសវនាការ ៖** ថ្ងៃសុក្រ ១២កើត ខែស្រាពណ៍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងថ្ងៃទី២០ ខែសីហា ឆ្នាំ២០២១វេលាម៉ោង ១៤ និង ០០ នាទី រសៀល។

**បញ្ញានីតិវិធី ៖**

នៅថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០២១ នាយកដ្ឋានវិវាទការងារ បានទទួលពាក្យបណ្តឹងរបស់ភាគីកម្មករនិយោជិត ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០២១ ស្តីពីការទាមទាររបស់កម្មករនិយោជិត សុំឱ្យក្រុមហ៊ុនកែលំអលក្ខខណ្ឌការងារចំនួន ១១ចំណុច។ បន្ទាប់ពីបានទទួលពាក្យបណ្តឹងនេះរួចមក នាយកដ្ឋានវិវាទការងារ បានចាត់មន្ត្រីជំនាញធ្វើការដោះស្រាយវិវាទការងារនេះជាបន្តបន្ទាប់ និងបានធ្វើការផ្សះផ្សានៅថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០២១ ដោយទទួលបានលទ្ធផលសះជានឹងគ្នា ចំនួន ៨ចំណុច។ ចំណុចមិនសះជា ចំនួន ៣ចំណុចនេះ ត្រូវបានបញ្ជូនមកក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី៩ ខែសីហា ឆ្នាំ២០២១ តាមរបាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៃក្រុមហ៊ុន ត្រាយអាំហ៊ិន ជ្រេហ្គូន (ខេមបូឌា) ឯ.ក លេខ ៥១៥ ក.ប/អក/វក ចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០២១។

បន្ទាប់ពីបានទទួលសំណុំរឿងនេះ ក្រុមអាជ្ញាកណ្តាល ត្រូវបានបង្កើតឡើងនៅថ្ងៃទី១១ ខែសីហា ឆ្នាំ២០២១។ លេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាលបានអញ្ជើញភាគីនិយោជក និងភាគីកម្មករនិយោជិតមកសវនាការ និងផ្សះផ្សាលើករណីមិនសះជា នៅថ្ងៃទី២០ ខែសីហា ឆ្នាំ២០២១ វេលាម៉ោង ២ និង ០០ នាទីរសៀល។ ដើម្បីគោរពតាមគោលការណ៍ណែនាំរបស់ក្រសួងសុខាភិបាលក្នុងការទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ-១៩ ជាពិសេសការរក្សាគម្លាតសុវត្ថិភាព ក្រុមអាជ្ញាកណ្តាលបានធ្វើសវនាការអនឡាញដោយប្រើប្រព័ន្ធស៊ូម (zoom) ដោយបានចែកបន្ទប់ រវាងភាគីនៃវិវាទ និងក្រុមអាជ្ញាកណ្តាលដាច់ដោយឡែកពីគ្នា។ ភាគីទាំងពីរមានវត្តមាននៅក្នុងសវនាការ តាមការអញ្ជើញរបស់លេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាល ប៉ុន្តែ ភាគីតំណាងនិយោជកបានបោះបង់សិទ្ធិឆ្លើយតបនៅក្នុងសវនាការ ដោយបញ្ជាក់ថា មិនមានសិទ្ធិសម្រេចនៅក្នុងសវនាការនេះទេ។

ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាណ្តាលសម្រេចបន្តនីតិវិធីសាវនាការ ដោយស្តាប់តែអំណះអំណាងពីភាគីកម្មករនិយោជិត។

នៅក្នុងសំណុំរឿងនេះ ភាគីជ្រើសរើសសេចក្តីបង្គាប់មិនជាប់កាតព្វកិច្ច។

នៅថ្ងៃសវនាការ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានកំណត់ថ្ងៃទី២៤ ខែសីហា ឆ្នាំ២០២១ ជាថ្ងៃផុតកំណត់ផ្តល់ឯកសារ ឬភស្តុតាង និងថ្ងៃទី២៦ ខែសីហា ឆ្នាំ២០២១ ជាថ្ងៃផុតកំណត់ជំទាស់ឯកសារ ឬភស្តុតាង។

កាលបរិច្ឆេទនៃការចេញសេចក្តីបង្គាប់អាជ្ញាកណ្តាល គឺនៅថ្ងៃទី៣១ ខែសីហា ឆ្នាំ២០២១។

ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការពិចារណា និងដោះស្រាយលើចំណុចវិវាទខាងលើនេះ ដោយផ្អែកលើភស្តុតាង និងការរកឃើញនៃអង្គហេតុ ដូចខាងក្រោម ៖

## ភស្តុតាង

សាក្សី និង អ្នកជំនាញក្រៅពីភាគី ៖ គ្មាន

## ឯកសារ វត្ថុតាង ដែលក្រុមអាជ្ញាកណ្តាលយកមកពិចារណាមាន

**ក- ឯកសារបានទទួលពីភាគីនិយោជក ៖**

១- សេចក្តីប្រកាសជូនដំណឹងបើកសហគ្រាស ក្រុមហ៊ុន ត្រាយអាំហ៊ិន ជ្រេហ្គូន (ខេមបូឌា) ឯ.ក លេខ ២៥៩ សរសេណ ចុះថ្ងៃពុធ ៥រោច ខែជេស្ឋ ឆ្នាំជូត ឯកស័ក ព.ស ២៥៦៤ ត្រូវនឹងថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២០។

២- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួមនៅក្រុមហ៊ុន ត្រាយអាំហ៊្វិន ជ្រេហ្គូន (ខេមបូឌា) ឯ.ក ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០២១។

៣- បទបញ្ជាផ្ទៃក្នុងក្រុមហ៊ុន ត្រាយអាំហ៊្វិន ជ្រេហ្គូន (ខេមបូឌា) ឯ.ក ចុះទិដ្ឋាការលេខ ១៤៤១ កបវ/ តក/ អធក ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៦ ដោយប្រធានមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជា-ជីវៈ ខេត្តតាកែវ។

៤- លក្ខន្តិកៈក្រុមហ៊ុន ត្រាយអាំហ៊្វិន ជ្រេហ្គូន (ខេមបូឌា) ឯ.ក បានតម្កល់ទុកលេខ ៣២៣៨/១៦ គវក ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១៦ នៅនាយកដ្ឋាននីតិវិធី និង ច្បាប់វិនិយោគ គ.វ.ក។

៥- លិខិតចុះថ្ងៃទី២៤ ខែសីហា ឆ្នាំ២០២១ របស់ក្រុមហ៊ុន ត្រាយអាំហ៊្វិន ជ្រេហ្គូន (ខេមបូឌា) ឯ.ក គោរពជូន ក្រុមប្រឹក្សាអាជ្ញាកណ្តាល ស្តីពីបង្ហាញភស្តុតាង និងអំណះអំណាងលើចំណុចទាមទារទាំង៣។

**ខ- ឯកសារបានទទួលពីភាគីកម្មករនិយោជិត ៖**

១- កំណត់ហេតុ ស្តីពីការសាកសួរព័ត៌មានតំណាងកម្មករនិយោជិតនៃក្រុមហ៊ុន ត្រាយអាំហ៊្វិន ជ្រេហ្គូន (ខេមបូឌា) ឯ.ក ចុះថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០២១ នៅនាយកដ្ឋានវិវាទការងារ។

២- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួមនៅក្រុមហ៊ុន ត្រាយអាំហ៊្វិន ជ្រេហ្គូន (ខេមបូឌា) ឯ.ក ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០២១។

៣- លក្ខន្តិកៈនៃសហជីពស្មារតីកម្មករខ្មែរក្រុមហ៊ុន ត្រាយអាំហ៊្វិន ជ្រេហ្គូន (ខេមបូឌា) ឯ.ក ចុះបញ្ជីលេខ ១២១១៧០០០៣ ចុះថ្ងៃទី០៥ ខែមេសា ឆ្នាំ២០១៧ ចេញដោយប្រធានមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តតាកែវ។

៤- លិខិតចុះថ្ងៃសុក្រ ៨រោច ខែបឋមាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥ ត្រូវនឹងថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០២១ របស់សហជីពស្មារតីកម្មករខ្មែរក្រុមហ៊ុន ត្រាយអាំហ៊្វិន ជ្រេហ្គូន (ខេមបូឌា) ឯ.ក គោរពចូលមក លោកនាយកក្រុមហ៊ុន ត្រាយអាំហ៊្វិន ជ្រេហ្គូន (ខេមបូឌា) ឯ.ក ស្តីពីសំណើសុំជួបពិភាក្សាដោះស្រាយ សម្របសម្រួលនូវលក្ខខណ្ឌការងាររួមចំនួន ១១ចំណុច។

៥- លិខិតពឹងពាក់ និងជួយអមប្រឹក្សាយោបល់ ចុះថ្ងៃព្រហស្បតិ៍ ៧រោច ខែបឋមាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥ ត្រូវនឹងថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០២១ របស់កម្មករនិយោជិតនៃក្រុមហ៊ុន ត្រាយអាំហ៊្វិន ជ្រេហ្គូន (ខេមបូឌា) ឯ.ក គោរពជូន លោកប្រធានសហព័ន្ធសហជីពស្មារតីកម្មករខ្មែរ ស្តីពីសុំពឹងពាក់ និងជួយអមប្រឹក្សាយោបល់ ក្នុងការសម្របសម្រួលជាមួយភាគីក្រុមហ៊ុន ក្រសួងការងារ ក្រុមប្រឹក្សាអាជ្ញាកណ្តាល តុលាការ អាជ្ញាធរ និងស្ថាប័នពាក់ព័ន្ធនូវករណីវិវាទការងាររបស់យើងខ្ញុំទាំងអស់គ្នា។

៦- លិខិតចាត់តាំងប្រតិភូចរចា ដោះស្រាយលក្ខខណ្ឌការងាររួមនៅក្រុមហ៊ុន ត្រាយអាំហ៊្វិន ជ្រេហ្គូន (ខេមបូឌា) ឯ.ក ចុះថ្ងៃពុធ ៦រោច ខែបឋមាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥ ត្រូវនឹងថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២១ របស់កម្មករនិយោជិតនៃក្រុមហ៊ុន ត្រាយអាំហ៊្វិន ជ្រេហ្គូន (ខេមបូឌា) ឯ.ក

THE ARBITRATION COUNCIL

គោរពចូលមក លោកនាយកក្រុមហ៊ុន ត្រាយអាំហ្វិន ជ្រេហ្គូន (ខេមបូឌា) ឯ.ក ស្តីពីសំណើសុំចាត់តាំងប្រតិភូចរចា ដើម្បីមានសិទ្ធិដោះស្រាយវិវាទការងាររួមរបស់យើងខ្ញុំ។

៧- វិញ្ញាបនបត្រចុះបញ្ជីអង្គការវិជ្ជាជីវៈរបស់សហជីពស្មារតីកម្មករខ្មែរក្រុមហ៊ុន ត្រាយអាំហ្វិន ជ្រេហ្គូន (ខេមបូឌា) ឯ.ក លេខ ៤៥៥ កបវ/តក ចុះថ្ងៃទី០៥ ខែមេសា ឆ្នាំ២០១៧។

៨- លិខិតលេខ ៤៤៤ ក.ប/អក/វក ចុះថ្ងៃពុធ ៦រោច ខែបឋមាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥ ត្រូវនឹងថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២១ របស់នាយកដ្ឋានវិវាទការងារ ជម្រាបមក ប្រធានសហជីពស្មារតីកម្មករខ្មែរក្រុមហ៊ុន ត្រាយអាំហ្វិន ជ្រេហ្គូន (ខេមបូឌា) ឯ.ក ស្តីពីការស្នើសុំទទួលស្គាល់ថ្នាក់ដឹកនាំសហជីព អាណត្តិទី២។

៩- សេចក្តីបង្គាប់អាជ្ញាកណ្តាលលេខ ០៤៩/២០-ត្រាយអាំហ្វិន ជ្រេហ្គូន (ខេមបូឌា) ឯ.ក ចុះថ្ងៃទី០៦ ខែតុលា ឆ្នាំ២០២០។

១០- លិខិតផ្ទេរសិទ្ធិរបស់សហព័ន្ធសហជីពស្មារតីកម្មករខ្មែរ ផ្ទេរសិទ្ធិឱ្យលោក អំ ពុទ្ធិ និងលោក ខែម ផានិត ជាមន្ត្រីសហព័ន្ធសហជីពស្មារតីកម្មករខ្មែរ ដើម្បីមានសិទ្ធិគ្រប់គ្រាន់ក្នុងកិច្ចការទំនាក់ទំនងជាមួយអង្គការវិជ្ជាជីវៈផ្សេងៗ រួមទាំងការដោះស្រាយវិវាទករណីក្រុមហ៊ុន ត្រាយអាំហ្វិន ជ្រេហ្គូន (ខេមបូឌា) ឯ.ក ចុះថ្ងៃទី២០ ខែសីហា ឆ្នាំ២០២១។

**គ- ឯកសារបានទទួលពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

១- របាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៅក្រុមហ៊ុន ត្រាយអាំហ្វិន ជ្រេហ្គូន (ខេមបូឌា) ឯ.ក លេខ ៥១៥ ក.ប/អក/វក ចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០២១។

២- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួមនៅក្រុមហ៊ុន ត្រាយអាំហ្វិន ជ្រេហ្គូន (ខេមបូឌា) ឯ.ក ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០២១។

៣- លិខិតបញ្ជាក់អ្នកតំណាងភាគីកម្មករនិយោជិតក្នុងការដោះស្រាយវិវាទការងាររួម នៃក្រុមហ៊ុន ត្រាយអាំហ្វិន ជ្រេហ្គូន (ខេមបូឌា) ឯ.ក លេខ ០០៤/២១ កប/អក/លបវ ចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០២១ របស់នាយកដ្ឋានវិវាទការងារ។

**ឃ- ឯកសារបានទទួលពីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល**

១- លិខិតអញ្ជើញភាគីនិយោជកចូលរួមសវនាការ លេខ ០៨៨ កប/អក/វក/លកអ. ចុះថ្ងៃសុក្រ ៥កើត ខែស្រាពណ៍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងថ្ងៃទី១៣ ខែសីហា ឆ្នាំ២០២១។

២- លិខិតអញ្ជើញភាគីកម្មករនិយោជិតចូលរួមសវនាការ លេខ ០៨៩ កប/អក/វក/លកអ. ចុះថ្ងៃសុក្រ ៥កើត ខែស្រាពណ៍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងថ្ងៃទី១៣ ខែសីហា ឆ្នាំ២០២១។

**អង្គហេតុ**

- ក្រោយពីបានពិនិត្យរបាយការណ៍នៃការផ្សះផ្សាវិវាទការងាររួម
- ក្រោយពីបានស្តាប់អំណះអំណាងរបស់តំណាងភាគីកម្មករនិយោជិត
- ក្រោយពីបានពិនិត្យឯកសារបន្ថែម

ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា ៖

- ក្រុមហ៊ុន ត្រាយអាំហ្វិន ជ្រេហ្វូន (ខេមបូឌា) ឯ.ក គឺជាក្រុមហ៊ុនដែលមានសកម្មភាពផ្នែកផលិតស្បែកជើង។ ក្រុមហ៊ុននេះមានដួលកម្មករនិយោជិតសរុបចំនួន ១៧៤៩ នាក់។ *(យោងតាមរបាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៃក្រុមហ៊ុន ត្រាយអាំហ្វិន ជ្រេហ្វូន (ខេមបូឌា) ឯ.ក លេខ ៥១៥ ក.ប/អក/វក ចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០២១)*
- នាយកដ្ឋានវិវាទការងារ បានចេញលិខិតបញ្ជាក់អ្នកតំណាងភាគីកម្មករនិយោជិត ក្នុងការដោះស្រាយវិវាទការងាររួម លេខ ០០៤/២១ ចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០២១ ដែលមានឈ្មោះកម្មករនិយោជិតចំនួន ៤ នាក់៖ ១. ម៉ុម ពន្លក, ២. ប្រាក់ ភក្តី, ៣. អឿន ស្រីពេជ្រ និង ៤. សាយ អូន។

**ចំណុចវិវាទទី ១ ៖ ភាគីកម្មករនិយោជិតទាមទារឱ្យនិយោជកអនុវត្តឡើងវិញចំពោះការអនុញ្ញាតឱ្យស្ត្រីមានផ្ទៃពោះទៅពិនិត្យសុខភាព ១ ថ្ងៃ ក្នុង ១ ខែ ដោយរក្សាប្រាក់ឈ្នួល និងប្រាក់អត្ថប្រយោជន៍ផ្សេងៗនៅពេញដដែល ដូចអ្វីដែលនិយោជកធ្លាប់ផ្តល់ឱ្យកម្មករនិយោជិតកន្លងមក**

- ភាគីកម្មករនិយោជិតបញ្ជាក់ទាមទារឱ្យនិយោជកអនុវត្តសេចក្តីបង្គាប់អាជ្ញាកណ្តាលលេខ ០៤៩/២០-ត្រាយអាំហ្វិន ជ្រេហ្វូន (ខេមបូឌា) ឯ.ក។
- ភាគីកម្មករនិយោជិតបានបញ្ជាក់មូលហេតុនៃការទាមទារថា និយោជកបានអនុវត្តតាមសេចក្តីបង្គាប់អាជ្ញាកណ្តាលលេខ ០៤៩/២០-ត្រាយអាំហ្វិន ជ្រេហ្វូន (ខេមបូឌា) ឯ.ក បានប្រហែល ៣ ទៅ ៤ ខែ ក្នុងការអនុញ្ញាតឱ្យកម្មករនិយោជិតជាស្ត្រីមានផ្ទៃពោះឈប់សម្រាកទៅពិនិត្យសុខភាពមួយថ្ងៃ ក្នុងមួយខែ។ ប៉ុន្តែក្រោយមកទៀត និយោជកបានបញ្ឈប់ការអនុវត្តនេះវិញ ដោយអនុញ្ញាតឱ្យកម្មករនិយោជិតជាស្ត្រីមានផ្ទៃពោះឈប់សម្រាកទៅពិនិត្យសុខភាពតែចំនួន ៥ ម៉ោង ក្នុងមួយខែវិញ ហើយបើឈប់សម្រាកលើសពីចំនួន ៥ ម៉ោងនេះ កម្មករនិយោជិតត្រូវប្រើប្រាស់ការឈប់សម្រាកប្រចាំឆ្នាំ ដែលការអនុវត្តនេះគឺផ្ទុយពីសេចក្តីបង្គាប់អាជ្ញាកណ្តាលខាងលើ។
- តំណាងភាគីនិយោជកបានបោះបង់សិទ្ធិឆ្លើយតបនៅក្នុងសវនាការ ដោយបញ្ជាក់ថាមិនមានសិទ្ធិសម្រេចនៅក្នុងសវនាការនេះទេ។

**ចំណុចវិវាទទី ២ ៖ ភាគីកម្មករនិយោជិតទាមទារឱ្យនិយោជកដំឡើងប្រាក់ឈ្នួលគោលចំនួន ២ ដុល្លារអាមេរិក ចំពោះប្រធានក្រុម ប្រធានផ្នែក ស៊ុបភ័រវ៉ាយស័រ(supervisor) ដូចកម្មករនិយោជិតដទៃ ស្របតាមប្រកាសរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ស្តីពីការដំឡើងប្រាក់ឈ្នួលអប្បបរមាសម្រាប់ឆ្នាំ២០២១**

- ភាគីកម្មករនិយោជិតបញ្ជាក់ការទាមទារឱ្យនិយោជកដំឡើងប្រាក់ឈ្នួលគោលចំនួន ២ ដុល្លារបន្ថែមដល់កម្មករនិយោជិតដែលជាប្រធានក្រុម, ប្រធានផ្នែក និងស៊ុបភ័រវ៉ាយស័រ(supervisor) ដែលមានប្រាក់ឈ្នួលគោលចាប់ពី ចំនួន ២០០ ដុល្លារអាមេរិក និងមានប្រាក់ឈ្នួលគោលលើសពីនេះ ស្របតាមប្រកាសរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ស្តីពីប្រាក់ឈ្នួលអប្បបរមាសម្រាប់ឆ្នាំ២០២១។
- ភាគីកម្មករនិយោជិតបានបញ្ជាក់មូលហេតុនៃការទាមទារថា ៖
  - យោងតាមប្រកាសស្តីពីប្រាក់ឈ្នួលអប្បបរមាសម្រាប់ឆ្នាំ២០២១ របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ កម្មករនិយោជិតទាំងអស់ត្រូវទទួលបានការដំឡើងប្រាក់ឈ្នួលគោលចំនួន ២ ដុល្លារអាមេរិកបន្ថែមទាំងអស់គ្នា។ ហេតុនេះ កម្មករនិយោជិតដែលជាប្រធានក្រុម, ប្រធានផ្នែក និងស៊ុបភ័រវ៉ាយស័រ(supervisor) ដែលមានចំនួនប្រហែល ៥០នាក់ និងមាន

ប្រាក់ឈ្នួលគោល ចាប់ពីចំនួន ២០០ ដុល្លារអាមេរិក និងមានប្រាក់ឈ្នួលគោលលើសពីនេះ ក៏ត្រូវទទួលបានការដំឡើងប្រាក់ឈ្នួលគោលបន្ថែមចំនួន ២ ដុល្លារអាមេរិក នេះផងដែរ។

- ម្យ៉ាងវិញទៀត ក្រុមហ៊ុនដទៃទៀតក៏បានដំឡើងប្រាក់ឈ្នួលគោល ២ ដុល្លារបន្ថែមនេះ ដល់កម្មករនិយោជិតរបស់គេដែលជាប្រធានក្រុម, ប្រធានផ្នែក និងស៊ុបភ័រវ៉ាយស័រ(supervisor) ស្របតាមប្រកាសខាងលើដែរ។

- តំណាងភាគីនិយោជកបានបោះបង់សិទ្ធិឆ្លើយតបនៅក្នុងសវនាការ ដោយបញ្ជាក់ថា មិនមានសិទ្ធិសម្រេចនៅក្នុងសវនាការនេះទេ។

**ចំណុចវិវាទទី ៣ ៖ ភាគីកម្មករនិយោជិតទាមទារឱ្យនិយោជកផ្តល់ប្រាក់ទ្រទ្រង់សុខភាព ចំនួន ៥ ដុល្លារអាមេរិក ដែលនិយោជកធ្លាប់ផ្តល់ជូនកន្លងមក**

- ភាគីកម្មករនិយោជិតបានបញ្ជាក់មូលហេតុនៃការទាមទារថា ៖
  - ចំនួនកម្មករនិយោជិតដែលទាមទារនៅក្នុងចំណុចនេះមានចំនួន ៣០០ នាក់ ដែលក្នុងនោះមានកម្មករនិយោជិតចំនួន ២០០ ជាសមាជិកសហជីព និងកម្មករនិយោជិតដែលមិនមែនជាសមាជិកសហជីពមានចំនួន ១០០ នាក់ ដែលបានផ្តិតមេដៃឱ្យសហជីពទាមទារចំណុចនេះ។
  - និយោជកបានអនុវត្តផ្តល់ជូនប្រាក់ទ្រទ្រង់សុខភាពចំនួន ៥ ដុល្លារអាមេរិក តាំងពីឆ្នាំ២០១៧ មកម្ល៉េះ តែនិយោជកបានបញ្ឈប់ការផ្តល់ជូននេះនៅដើមឆ្នាំ២០២០។
  - ចាប់ពីឆ្នាំ២០២១នេះ នៅពេលចប់កិច្ចសន្យាការងារចាស់ដែលមានថិរវេលា ២ ឆ្នាំ និយោជកតម្រូវឱ្យកម្មករនិយោជិតចុះកិច្ចសន្យាការងារសារជាថ្មីជាមួយនិយោជក ហើយនិយោជកក៏លែងផ្តល់ប្រាក់ទ្រទ្រង់សុខភាពនេះដល់កម្មករនិយោជិតដែរ ដោយផ្អែកលើការប្តូរកិច្ចសន្យាការងារថ្មីនេះ។ ចំពោះការចុះកិច្ចសន្យាការងារសារជាថ្មីនេះ និយោជកគម្រាមបញ្ឈប់កម្មករនិយោជិតពីការងារ ប្រសិនបើកម្មករនិយោជិតណាមិនព្រមចុះកិច្ចសន្យាការងារថ្មីជាមួយនិយោជក។
  - កម្មករនិយោជិតដែលមិនទាន់ចប់កិច្ចសន្យាការងារចាស់ដែលមានថិរវេលា ២ ឆ្នាំ នៅតែទទួលបានប្រាក់រង្វាន់ទ្រទ្រង់សុខភាពចំនួន ៥ ដុល្លារអាមេរិក ដដែល។
- តំណាងភាគីនិយោជកបានបោះបង់សិទ្ធិឆ្លើយតបនៅក្នុងសវនាការ ដោយបញ្ជាក់ថា មិនមានសិទ្ធិសម្រេចនៅក្នុងសវនាការនេះទេ។

## ហេតុផលនៃសេចក្តីសម្រេច ៖

**ចំណុចវិវាទទី ១ ៖ ភាគីកម្មករនិយោជិតទាមទារឱ្យនិយោជកអនុវត្តសេចក្តីបង្គាប់អាជ្ញាកណ្តាល លេខ ០៤៩/២០-ត្រាយអាំហ្វិន ជ្រេហ្គន (ខេមបូឌា) ឯ.ក**

តំណាងភាគីនិយោជកបានបោះបង់សិទ្ធិឆ្លើយតបនៅក្នុងសវនាការ ដោយបញ្ជាក់ថាមិនមានសិទ្ធិសម្រេចនៅក្នុងសវនាការនេះទេ។ ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលនឹងធ្វើការពិចារណាដូចខាងក្រោម ៖

តើក្រុមប្រឹក្សាអាជ្ញាកណ្តាលមានសមត្ថកិច្ចសម្រេចឱ្យនិយោជកអនុវត្តសេចក្តីបង្គាប់អាជ្ញាកណ្តាល លេខ ០៤៩/២០-ត្រាយអាំហ្វិន ជ្រេហ្គន (ខេមបូឌា) ឯ.ក ដែរ ឬទេ?

ចំណុចទី១ មាត្រា ៣៥៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦ ចែងថា ៖ "*ដើម្បីធ្វើការអនុវត្តដោយបង្ខំ ដោយផ្អែកលើសេចក្តីសម្រេចមជ្ឈត្តករ ទោះបីជាសេចក្តីសម្រេចមជ្ឈត្តកក្នុងប្រទេសក៏ដោយ សេចក្តីសម្រេចមជ្ឈត្តកបរទេសក៏ដោយ ត្រូវទទួលដីកាសម្រេចអនុវត្តរបស់តុលាការនៅព្រះរាជាណាចក្រកម្ពុជា*"។

ផ្អែកតាមចំណុចទី១ មាត្រា ៣៥៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦ ខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា មានតែស្ថាប័នតុលាការប៉ុណ្ណោះ ដែលមានសមត្ថកិច្ចក្នុងការសម្រេចឱ្យភាគីណាមួយនៃវិវាទអនុវត្តនូវសេចក្តីបង្គាប់អាជ្ញាកណ្តាលនៅក្នុង និងក្រៅប្រទេស ដោយរួមទាំងសេចក្តីបង្គាប់របស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលផងដែរ។ ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលពុំមានសមត្ថកិច្ចក្នុងការអនុវត្តបង្ខំឱ្យភាគីនៃវិវាទអនុវត្តសេចក្តីបង្គាប់អាជ្ញាកណ្តាលដែលបានចេញនោះទេ។ *(សូមមើលសេចក្តីបង្គាប់អាជ្ញាកណ្តាលលេខ ១៨/១៣-អឹម វ៉េ (សាខាទី១) ហេតុផលនៃចំណុចវិវាទទី១, លេខ ៣៥២/១៤-វ៉ាយអូលែត អឹកែលែ (ខេមបូឌា) ហេតុផលនៃចំណុចវិវាទទី១, លេខ ២៣៧/១៦-ហ្សិណា-ដាយជុង (ខេមបូឌា) អេឡិចត្រូនិច, លេខ ០៤៣/១៩ - ជាវ ហ៊ុយ អ៊ិនដាសស្រ្ទៀល ហេតុផលនៃចំណុចវិវាទទី១២)*

ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងមុនៗ បានសម្រេចបដិសេធពិចារណាលើការទាមទាររបស់ភាគីកម្មករនិយោជិតឱ្យនិយោជកអនុវត្តសេចក្តីបង្គាប់អាជ្ញាកណ្តាល។ *(សូមមើលសេចក្តីបង្គាប់អាជ្ញាកណ្តាលលេខ ១៨/១៣-អឹម វ៉េ (សាខាទី១) ហេតុផលនៃចំណុចវិវាទទី១, លេខ ៣៥២/១៤-វ៉ាយអូលែត អឹកែលែ (ខេមបូឌា) ហេតុផលនៃចំណុចវិវាទទី១, លេខ ២៣៧/១៦-ហ្សិណា-ដាយជុង (ខេមបូឌា) អេឡិចត្រូនិច, លេខ ០៤៣/១៩ - ជាវ ហ៊ុយ អ៊ិនដាសស្រ្ទៀល ហេតុផលនៃចំណុចវិវាទទី១២)*

ដូចនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេច បដិសេធពិចារណាការទាមទាររបស់ភាគីកម្មករនិយោជិតឱ្យនិយោជកអនុវត្តសេចក្តីបង្គាប់អាជ្ញាកណ្តាលលេខ ០៤៩/២០-ត្រាយអាំហ្វិន ជ្រេហ្គន (ខេមបូឌា) ឯ.ក។

**ចំណុចវិវាទទី ២ ៖ ភាគីកម្មករនិយោជិតទាមទារ ឱ្យនិយោជកដំឡើងប្រាក់ឈ្នួលគោលចំនួន ២ ដុល្លារបន្ថែម ជូនដល់កម្មករនិយោជិតដែលជាប្រធានក្រុម, ប្រធានផ្នែក និងស៊ុប(supervisor) ដែលមានប្រាក់ឈ្នួលគោលចាប់ពីចំនួន ២០០ ដុល្លារអាមេរិក និងមានប្រាក់ឈ្នួលគោលលើសពីនេះ ស្របតាមប្រកាសរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ស្តីពីប្រាក់ឈ្នួលអប្បបរមាសម្រាប់ឆ្នាំ២០២១**

តំណាងភាគីនិយោជកបានបោះបង់សិទ្ធិឆ្លើយតបនៅក្នុងសវនាការ ដោយបញ្ជាក់ថាមិនមានសិទ្ធិសម្រេចនៅក្នុងសវនាការនេះទេ។ ហេតុនេះ ក្រុមប្រឹក្សានឹងធ្វើការពិចារណាដូចខាងក្រោម ៖

តើនិយោជកមានកាតព្វកិច្ចដំឡើងប្រាក់ឈ្នួលគោលចំនួន ២ ដុល្លារបន្ថែម ជូនដល់កម្មករនិយោជិតដែលជាប្រធានក្រុម, ប្រធានផ្នែក និងស៊ុប(supervisor) ដែលមានប្រាក់ឈ្នួលគោលចាប់ពី ចំនួន ២០០ ដុល្លារអាមេរិក និងមានប្រាក់ឈ្នួលគោលលើសពីនេះ ស្របតាមប្រកាសរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ស្តីពីប្រាក់ឈ្នួលអប្បបរមាសម្រាប់ឆ្នាំ២០២១ ដែរ ឬទេ?

កថាខណ្ឌទី២ មាត្រា ១០៧ នៃច្បាប់ស្តីពីការងារ ចែងថា ៖ "*២- ប្រាក់ឈ្នួលអប្បបរមាដែលត្រូវធានា ត្រូវកំណត់ដោយប្រកាសក្រសួងទទួលបន្ទុកវិស័យការងារ បន្ទាប់ពីបានទទួលយោបល់របស់គណៈកម្មការប្រឹក្សាការងារ...*"។

ប្រការ ១ នៃប្រកាសលេខ ៣០៣/២០ ក.ប/ប្រ.ក.ខ.ល ស្តីពីការកំណត់ប្រាក់ឈ្នួលអប្បបរមាសម្រាប់កម្មករនិយោជិតផ្នែកវាយនភណ្ឌ កាត់ដេរ និងផលិតស្បែកជើង សម្រាប់ឆ្នាំ២០២១ ចែងថា ៖ "*ត្រូវបានបន្ថែម*

THE ARBITRATION COUNCIL

*ទឹកប្រាក់ចំនួន ២(ពីរ) ដុល្លារអាមេរិក លើទឹកប្រាក់ចំនួន ១៩០ (មួយរយកៅសិប) ដុល្លារអាមេរិក ដែលបានស្នើឡើងដោយក្រុមប្រឹក្សាជាតិប្រាក់ឈ្នួលអប្បបរមា ជាប្រាក់ឈ្នួលអប្បបរមាសម្រាប់កម្មករនិយោជិតផ្នែកវាយនភណ្ឌ កាត់ដេរ និងផលិតស្បែកជើង ក្នុងមួយខែ សម្រាប់ឆ្នាំ២០២១។*

*ប្រាក់ឈ្នួលអប្បបរមាសម្រាប់កម្មករនិយោជិតផ្នែកវាយនភណ្ឌ កាត់ដេរ និងផលិតស្បែកជើង សម្រាប់ឆ្នាំ២០២១ ត្រូវបានកំណត់ជាផ្លូវការនូវទឹកប្រាក់ចំនួន ១៩២ (មួយរយកៅសិបពីរ) ដុល្លារអាមេរិក ក្នុងមួយខែ"។*

យោងតាមមាត្រា ១០៧ នៃច្បាប់ស្តីពីការងារ និងប្រការ ១ នៃប្រកាសលេខ ៣០៣/២០ ខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ប្រាក់ឈ្នួលអប្បបរមាដែលត្រូវធានា គឺត្រូវកំណត់ដោយប្រកាសរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ហើយសម្រាប់ឆ្នាំ២០២១ គឺត្រូវបន្ថែមទឹកប្រាក់ចំនួន ២ ដុល្លារអាមេរិក លើទឹកប្រាក់ចំនួន ១៩០ ដុល្លារអាមេរិក ដែលបានស្នើឡើងដោយក្រុមប្រឹក្សាជាតិប្រាក់ឈ្នួលអប្បបរមា ដែលនាំឱ្យប្រាក់ឈ្នួលអប្បបរមាសម្រាប់កម្មករនិយោជិតផ្នែកវាយនភណ្ឌ កាត់ដេរ និងផលិតស្បែកជើង សម្រាប់ឆ្នាំ២០២១ គឺមានចំនួន ១៩២ ដុល្លារអាមេរិក ក្នុងមួយខែ។

នៅក្នុងសវនាការ ភាគីកម្មករនិយោជិតយល់ឃើញថា ប្រកាសខាងលើកំណត់ឱ្យនិយោជកផ្តល់ប្រាក់ចំនួន ២ ដុល្លារអាមេរិក បន្ថែមទៀត ជូនកម្មករនិយោជិតទាំងអស់ រួមទាំងកម្មករនិយោជិតដែលជាប្រធានក្រុម, ប្រធានផ្នែក និងស៊ុបភ័រវ៉ាយស័រ ដែលមានប្រាក់ឈ្នួលគោលចាប់ពី ២០០ ដុល្លារអាមេរិក និងមានប្រាក់ឈ្នួលគោលលើសពីនេះផងដែរ។ ករណីនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា និយោជកបានផ្តល់ប្រាក់ឈ្នួលគោលជូនដល់កម្មករនិយោជិតដែលជាប្រធានក្រុម, ប្រធានផ្នែក និងស៊ុប(supervisor) លើសពីប្រាក់ឈ្នួលគោលអប្បរមាដែលបានកំណត់រួចហើយ ហើយការផ្តល់ជូននេះគឺមានលក្ខណៈប្រសើរជាងប្រកាសផងដែរ។

សរុបមក ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេច បដិសេធការទាមទាររបស់ភាគីកម្មករនិយោជិតឱ្យនិយោជកដំឡើងប្រាក់ឈ្នួលគោលចំនួន ២ ដុល្លាបន្ថែម ជូនដល់កម្មករនិយោជិតដែលជាប្រធានក្រុម, ប្រធានផ្នែក និងស៊ុប(supervisor) ដែលមានប្រាក់ឈ្នួលគោលចាប់ពី ចំនួន ២០០ ដុល្លារអាមេរិក និងមានប្រាក់ឈ្នួលគោលលើសពីនេះ ស្របតាមប្រកាសរបស់ក្រសួងការងារស្តីពីប្រាក់ឈ្នួលអប្បបរមាសម្រាប់ឆ្នាំ២០២១។

**ចំណុចវិវាទទី ៣ ៖ ភាគីកម្មករនិយោជិតទាមទារឱ្យនិយោជកផ្តល់ប្រាក់ទ្រទ្រង់សុខភាព ចំនួន ៥ ដុល្លារអាមេរិក ដែលនិយោជកធ្លាប់ផ្តល់ជូនកន្លងមក**

យោងតាមអង្គហេតុ ភាគីកម្មករនិយោជិតបានអះអាងថា និយោជកបានអនុវត្តផ្តល់ជូនប្រាក់ទ្រទ្រង់សុខភាពចំនួន ៥ ដុល្លារអាមេរិក តាំងពីឆ្នាំ២០១៧ មកម្ល៉េះ តែនិយោជកបានបញ្ឈប់ការផ្តល់ជូននេះនៅដើមឆ្នាំ២០២០។ ចាប់ពីឆ្នាំ២០២១ នៅពេលកិច្ចសន្យាការងារចាស់របស់កម្មករនិយោជិតដែលមានថិរវេលា ២ ឆ្នាំ និយោជកតម្រូវឱ្យកម្មករនិយោជិតចុះកិច្ចសន្យាការងារសារជាថ្មីជាមួយនិយោជក ហើយនិយោជកក៏លែងផ្តល់ប្រាក់ទ្រទ្រង់សុខភាពនេះដល់កម្មករនិយោជិតផងដែរ។ បន្ថែមពីលើការអះអាងនេះ ភាគីកម្មករនិយោជិតបានបញ្ជាក់ថានឹងដាក់ភស្តុតាងជូនក្រុមប្រឹក្សាអាជ្ញាកណ្តាល ដើម្បីបញ្ជាក់ពីការធ្លាប់ផ្តល់ជូនប្រាក់ទ្រទ្រង់សុខភាពនេះ។

ករណីនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ការលើកឡើងរបស់ភាគីកម្មករនិយោជិតខាងលើ គឺមិនមានមូលដ្ឋាន និងអង្គហេតុគ្រប់គ្រាន់ ដើម្បីឱ្យក្រុមប្រឹក្សាអាជ្ញាណ្តាលធ្វើការពិចារណាថា តើការដែល

THE ARBITRATION COUNCIL

និយោជកបញ្ឈប់ផ្តល់ប្រាក់ទ្រទ្រង់សុខភាពចំនួន ៥ ដុល្លារអាមេរិក នេះ គឺធ្វើឡើងដោយត្រឹមត្រូវ ឬខុសច្បាប់នោះទេ។

ដូចនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេច បដិសេធពិចារណាការទាមទាររបស់ភាគីកម្មករនិយោជិត ឱ្យនិយោជកផ្តល់ប្រាក់ទ្រទ្រង់សុខភាព ចំនួន ៥ ដុល្លារអាមេរិក ដែលនិយោជកធ្លាប់ផ្តល់ជូនកន្លងមក។

យោងតាមការបង្ហាញភស្តុតាង អង្គហេតុ អង្គច្បាប់ និងហេតុផល ដូចបានបញ្ជាក់ខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេចចេញសេចក្តីបង្គាប់ ដូចតទៅ ៖

## សម្រេច

**ចំណុចវិវាទទី ១ ៖**

- បដិសេធពិចារណាការទាមទាររបស់ភាគីកម្មករនិយោជិត ឱ្យនិយោជកអនុវត្តសេចក្តីបង្គាប់អាជ្ញាកណ្តាល លេខ ០៤៩/២០-ត្រាយអាំហ្វិន ជ្រេហ្គន (ខេមបូឌា) ឯ.ក។

**ចំណុចវិវាទទី ២ ៖**

- បដិសេធការទាមទាររបស់ភាគីកម្មករនិយោជិត ឱ្យនិយោជកដំឡើងប្រាក់ឈ្នួលគោល ចំនួន ២ដុល្លារបន្ថែម ជូនដល់កម្មករនិយោជិតដែលជាប្រធានក្រុម, ប្រធានផ្នែក និងស៊ុប(supervisor) ដែលមានប្រាក់ឈ្នួលគោលចាប់ពីចំនួន ២០០ដុល្លារអាមេរិក និងមានប្រាក់ឈ្នួលគោលលើសពីនេះ ស្របតាមប្រកាសរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ស្តីពីប្រាក់ឈ្នួលអប្បបរមាសម្រាប់ឆ្នាំ២០២១។

**ចំណុចវិវាទទី ៣ ៖**

- បដិសេធពិចារណាការទាមទាររបស់ភាគីកម្មករនិយោជិត ឱ្យនិយោជកផ្តល់ប្រាក់ទ្រទ្រង់សុខភាព ចំនួន ៥ ដុល្លារអាមេរិក ដែលនិយោជកធ្លាប់ផ្តល់ជូនកន្លងមក។

**ប្រភេទនៃសេចក្តីបង្គាប់ ៖ សេចក្តីបង្គាប់មិនជាប់កាតព្វកិច្ច**

*សេចក្តីបង្គាប់នេះ នឹងក្លាយជាស្ថាពរ បន្ទាប់ពីថ្ងៃជូនដំណឹងអំពីសេចក្តីបង្គាប់ ចំនួន ០៨ថ្ងៃ បើសិនជាមិនមានភាគីណាមួយដាក់ពាក្យជំទាស់ជាលាយលក្ខណ៍អក្សរទៅរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ តាមរយៈលេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាល ក្នុងរយៈពេលនេះទេ។*

**ហត្ថលេខារបស់សមាជិកក្រុមអាជ្ញាកណ្តាល**

អាជ្ញាកណ្តាលជ្រើសរើសដោយភាគីនិយោជក ៖

ឈ្មោះ ៖ **អ៊ុខ សុទ្ធី**

ហត្ថលេខា ៖ ------------------------------

អាជ្ញាកណ្តាលជ្រើសរើសដោយភាគីកម្មករនិយោជិត ៖

ឈ្មោះ ៖ **អន ណាន**

ហត្ថលេខា ៖------------------------------

ប្រធានក្រុមអាជ្ញាកណ្តាល ៖

ឈ្មោះ ៖ **រុន សារ៉ាយ**

ហត្ថលេខា ៖ ------------------------------

THE ARBITRATION COUNCIL